**ព្រះរាជាណាចក្រកម្ពុជា**
**Kingdom of Cambodia**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Nation Religion King**

លេខ / N°.០០៥/២០.ស.ជ.ក.

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មាធិការគ្រប់គ្រងហានិភ័យ
## នៃក្រុមប្រឹក្សាភិបាលរបស់សាជីវកម្មធានាឥណទានកម្ពុជា

## ក្រុមប្រឹក្សាភិបាល

- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ប្រកាសឱ្យប្រើច្បាប់ ស្តីពីសហគ្រាសពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៧១ អនក្រ.បក ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១១ ស្តីពីបំពេញបន្ថែមអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៤០ អនក្រ.បក ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២០ ស្តីពីការបង្កើតសាជីវកម្មធានាឥណទានកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៩២៦ អនក្រ.តត ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០ ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល និងមន្ត្រីត្រួតពិនិត្យរដ្ឋអមសាជីវកម្មធានាឥណទានកម្ពុជា
- បានឃើញលក្ខន្តិកៈសាជីវកម្មធានាឥណទានកម្ពុជា ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២០
- យោងតាមតម្រូវការចាំបាច់របស់សាជីវកម្មធានាឥណទានកម្ពុជា



មហាវិថីព្រះនរោត្តម, អគារអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា (ជាន់ទី២៥), រាជធានីភ្នំពេញ
Preah Norodom Blvd, General Department of Customs and Excise of Cambodia Building (25th Floor), Phnom Penh.

## សម្រេច

**ប្រការ ១ .-**

ត្រូវបានបង្កើត គណៈកម្មាធិការគ្រប់គ្រងហានិភ័យ នៃក្រុមប្រឹក្សាភិបាលរបស់សាជីវកម្មធានាឥណទានកម្ពុជា (**ស.ធ.ក.**) ដើម្បីធានាបាននូវចីរភាព, ស្ថិរភាព, ភាពរឹងមាំ, និងគ្រប់គ្រងបានកម្រិតហានិភ័យ ដែលមានក្នុងក្របខ័ណ្ឌគ្រប់គ្រងហានិភ័យ និងអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ ២ .-**

គណៈកម្មាធិការគ្រប់គ្រងហានិភ័យ មានសមាសភាព ដូចខាងក្រោម÷

- សមាជិកក្រុមប្រឹក្សាភិបាល តំណាងពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធាន
- សមាជិកក្រុមប្រឹក្សាភិបាល តំណាងពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សមាជិក
- សមាជិកក្រុមប្រឹក្សាភិបាល តំណាងមកពីធនាគារជាតិនៃកម្ពុជា សមាជិក

ក្រុមប្រឹក្សាភិបាល អាចតែងតាំងសមាសភាពបន្ថែម នៃគណៈកម្មាធិការគ្រប់គ្រងហានិភ័យតាមការចាំបាច់។

សមាសភាពជាក់ស្តែង នៃគណៈកម្មាធិការគ្រប់គ្រងហានិភ័យ ត្រូវកំណត់ដោយសេចក្តីសម្រេចដាច់ដោយឡែករបស់ក្រុមប្រឹក្សាភិបាល។

**ប្រការ ៣ .-**

គណៈកម្មាធិការគ្រប់គ្រងហានិភ័យ មានតួនាទី និងភារកិច្ច ដូចខាងក្រោម÷

- គាំទ្រក្រុមប្រឹក្សាភិបាលក្នុងការត្រួតពិនិត្យ, អនុម័ត, និងអនុវត្តគោលនយោបាយហានិភ័យ និងក្របខ័ណ្ឌនៃការគ្រប់គ្រងហានិភ័យ និងអនុលោមភាព
- ធានាថា **ស.ធ.ក.** មានកម្រិតហានិភ័យសមស្រប ដោយថ្លឹងថ្លែងរវាងអត្រាហានិភ័យ និងអត្រាទិន្នផលទទួលបានពីសកម្មភាពអាជីវកម្ម
- ត្រួតពិនិត្យអនុលោមភាពនៃការអនុវត្តគោលនយោបាយគ្រប់គ្រងហានិភ័យ
- វាយតម្លៃ និងផ្តល់យោបល់ជូនក្រុមប្រឹក្សាភិបាលអំពីកម្រិតហានិភ័យរបស់ **ស.ធ.ក.**

- ត្រួតពិនិត្យការអនុវត្តការងាររបស់គណៈគ្រប់គ្រង **ស.ធ.ភ.** ក្នុងការគ្រប់គ្រងហានិភ័យ នៅក្នុងក្របខ័ណ្ឌនៃការកំណត់ថ្លៃ, និងការអភិវឌ្ឍផលិតផល, ព្រមទាំងកត្តាហានិភ័យផ្សេងៗទៀតពាក់ព័ន្ធប្រភេទអាជីវកម្ម និងកម្រិតហានិភ័យតាមវិស័យ ដែលត្រូវផ្តល់ការធានាឥណទាន
- ស្នើឡើងនូវគោលការណ៍, វិធាន, និងដំណោះស្រាយនានា ដើម្បីធានាបាននូវចីរភាព, ស្ថិរភាព, និងភាពរឹងមាំរបស់ **ស.ធ.ភ.** ជូនទៅក្រុមប្រឹក្សាភិបាល
- អនុវត្តកិច្ចការផ្សេងទៀត តាមការណែនាំរបស់ក្រុមប្រឹក្សាភិបាល។

**ប្រការ ៤ .-**

គណៈកម្មាធិការគ្រប់គ្រងហានិភ័យ ត្រូវរៀបចំកិច្ចប្រជុំយ៉ាងតិច ១ដង ក្នុង ១ត្រីមាស។

គណៈកម្មាធិការគ្រប់គ្រងហានិភ័យ អាចរៀបចំកិច្ចប្រជុំតាមការចាំបាច់ តាមសំណើររបស់ប្រធាន ឬ សមាជិកភាគច្រើន។

**ប្រការ ៥ .-**

សមាជិកទាំងអស់ត្រូវចូលរួមកិច្ចប្រជុំតាមការអញ្ជើញរបស់ប្រធាន។ សមាជិកអវត្តមាន មិនអាចចាត់អ្នកតំណាង ដើម្បីចូលរួមកិច្ចប្រជុំគណៈកម្មាធិការគ្រប់គ្រងហានិភ័យបានទេ។

គណៈកម្មាធិការគ្រប់គ្រងហានិភ័យ អាចអញ្ជើញថ្នាក់ដឹកនាំ បុគ្គលិករបស់ **ស.ធ.ភ.** និងអ្នកជំនាញការ ព្រមទាំងភាគីពាក់ព័ន្ធ ចូលរួមកិច្ចប្រជុំគណៈកម្មាធិការគ្រប់គ្រងហានិភ័យ តាមការចាំបាច់។

គណៈកម្មាធិការគ្រប់គ្រងហានិភ័យ អាចរៀបចំកិច្ចប្រជុំបាន លុះត្រាតែមានវត្តមានរបស់សមាសភាពភាគច្រើនចូលរួម។

**ប្រការ ៦ .-**

គណៈកម្មាធិការគ្រប់គ្រងហានិភ័យ ត្រូវរៀបចំមុខងារ និងភារកិច្ច (Terms of Reference) របស់គណៈកម្មាធិការគ្រប់គ្រងហានិភ័យ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាល ពិនិត្យ និងសម្រេច។

**ប្រការ ៧ .-**

គណៈកម្មាធិការគ្រប់គ្រងហានិភ័យ ត្រូវមានរបាយការណ៍នៃរាល់កិច្ចប្រជុំ និងត្រូវផ្តល់របាយការណ៍នេះជូនក្រុមប្រឹក្សាភិបាល យ៉ាងយូរ ១៥ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីកិច្ចប្រជុំ។

**ប្រការ ៨ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៩ .-**

គណៈកម្មាធិការគ្រប់គ្រងហានិភ័យ មានភារកិច្ចអនុវត្តតាមសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

*ថ្ងៃសុក្រ ១១កើត ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤*

*រាជធានីភ្នំពេញ ថ្ងៃ ២៥ ខែ ធ្នូ ឆ្នាំ២០២០*

**សាជីវកម្មធានាឥណទានកម្ពុជា**

**ប្រធានក្រុមប្រឹក្សាភិបាល**

CGCC

CREDIT GUARANTEE CORPORATION OF CAMBODIA PLC

**រស់ សីលវ៉ា**

**ចម្លងជូន៖**

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ធនាគារជាតិនៃកម្ពុជា
- សមាជិកក្រុមប្រឹក្សាភិបាលរបស់ **ស.ធ.ក.**
- ឯកសារ-កាលប្បវត្តិ